**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ :...៨៤០ ទ.ភ.ក.ក

រាជធានីភ្នំពេញ ថ្ងៃទី...១១... ខែ...តុលា... ឆ្នាំ២០០៦

# ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
## ជំរាបមក
## លោក សៅ វណ្ណសី ប្រធានអង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច

**កម្មវត្ថុ** : អំពីការសុំចុះបញ្ជីរបស់ ***អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច*** នៅក្រសួងមហាផ្ទៃ ។

**យោង** : លិខិតលេខ ***00១/0៦-ICSO*** ចុះថ្ងៃទី***0៧*** ខែ***កក្កដា*** ឆ្នាំ***២00៦*** ស្តីពីការសុំចុះបញ្ជីរបស់ ***អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច*** ។

តបតាមកម្មវត្ថុ និងយោងខាងលើ សូមជំរាបលោកប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី ***អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច*** ដែលមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាល នៅផ្ទះលេខ ***៨១B*** ផ្លូវលេខ***៥៧*** សង្កាត់***បឹងកេងកងទី១*** ខណ្ឌ***ចំការមន រាជធានីភ្នំពេញ*** នោះហើយ ។ ***អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច*** ត្រូវអនុវត្តតាមលក្ខន្តិកៈដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាអង្គការអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបំរើអោយគណបក្សនយោបាយ និងមិនធ្វើជាឧបករណ៍គណបក្សនយោបាយ ។

ក្រោយពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីអោយបានត្រឹមត្រូវតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមលោកប្រធានជ្រាបជាព័ត៌មាន ។
សូមលោកប្រធាន ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**ស ខេង**

***ចម្លងជូន :***
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាប "
- សាលាក្រុងភ្នំពេញ
  " ដើម្បីមុខការ "
- ឯកសារ-កាលប្បវត្តិ